# លក្ខខណ្ឌ និងខចែងនៃគណនីប្រាក់បញ្ញើ

## មាត្រា ១. ការអនុវត្តនៃលក្ខខណ្ឌ និងខចែង

លក្ខខណ្ឌ និងខចែងទាំងនេះត្រូវបានអនុវត្តចំពោះប្រតិបត្តិការជាមួយ**ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក,** (តទៅនេះហៅថា "**ធនាគារ**") ក្រោម "**គណនីប្រាក់បញ្ញើតាមតម្រូវការ**" (តទៅនេះហៅថា "**គណនី**")។

## មាត្រា ២. បុគ្គលដែលអាចមានសិទ្ធិប្រើប្រាស់

គណនីនេះអាចប្រើប្រាស់បានសម្រាប់រូបវន្តបុគ្គល (មានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ) អាជីវកម្មបុគ្គល សាជីវកម្ម ធនាគារ/គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការក្រៅរដ្ឋាភិបាល។

## មាត្រា ៣. លក្ខខណ្ឌនៃគណនី

| ប្រភេទ | មាតិកា |
|---|---|
| **ប្រភេទគណនី** | ប្រាក់បញ្ញើ |
| **ប្រាក់តម្កល់ដំបូង** | 0.00ដុល្លារ/0,00រៀល (អាចដាក់ប្រាក់បញ្ញើគ្មានការកំណត់) |
| **រូបិយប័ណ្ណ** | ដុល្លារ/រៀល |
| **ចំនួនប្រាក់បញ្ញើ** | មិនកំណត់ |
| **អត្រាការប្រាក់** | អនុវត្តដោយផ្អែកលើអត្រាការប្រាក់ស្តង់ដារដែលចេញដោយធនាគារ (អាចផ្ទៀងផ្ទាត់តាមរយៈគេហទំព័រ៖ www.shinhan.com.kh) |
| **លក្ខខណ្ឌធ្វើប្រតិបត្តិការ** | អាចដាក់ ឬដកប្រាក់បានគ្រប់ពេលអាស្រ័យទៅលើសមតុល្យក្នុងគណនីដែលមាន |
| **ការទូទាត់ការប្រាក់** | ធនាគារទូទាត់ការប្រាក់ជូនអតិថិជនជារៀងរាល់ខែ ឬ នៅពេលបិទគណនី (រយៈពេលទូទាត់ការប្រាក់៖ ជារៀងរាល់ចុងខែ នៃឆ្នាំ) |
| **លក្ខខណ្ឌបិទគណនីមុនកាលកំណត់** | ២០.០០ដុល្លារ/៨០,០០០រៀល កំរៃសេវាប្រសិនបើការបិទគណនីប្រាក់បញ្ញើតាមតម្រូវការមុនរយៈពេល៣ខែ បន្ទាប់ពីថ្ងៃបើកគណនី |
| **ពន្ធលើប្រាក់ចំណូលនៃការប្រាក់** | ៤% សំរាប់និវាសនជន/ ១៤% សំរាប់អនិវាសនជន |
| **ការដាក់ប្រាក់បញ្ញើ** | គ្រប់សាខាទាំងអស់របស់ធនាគារស៊ិនហាន/ម៉ាស៊ីនអេធីអឹម/តាមរយៈធនាគារផ្សេងៗ |
| **អត្ថប្រយោជន៍បន្ថែម** | មិនគិតកំរៃនៃសេវាថែទាំប្រចាំឆ្នាំ /អ៊ីនធឺណិត ឬសេវាធនាគារចល័ត |

## មាត្រា ៤. ប្រតិបត្តិការប្រាក់បញ្ញើ

គណនីនេះត្រូវបានដំណើរការជាប្រាក់បញ្ញើ។

# លក្ខខណ្ឌ និងខចែងនៃគណនីបញ្ញើ

## មាត្រា ១. វិសាលភាពនៃការអនុវត្ត

១. "គណនីបញ្ញើតាមតម្រូវការ" សំដៅលើ "គណនី" មានន័យថាជាគណនីដាក់ប្រាក់ណាមួយដោយគ្មានរយៈពេលកំណត់ក្នុងការដាក់ប្រាក់, ដែលអនុញ្ញាតឱ្យអតិថិជនធ្វើការដាក់ប្រាក់/ដកប្រាក់បានតាមតម្រូវការ។
២. រាល់ចំណុចដែលមិនបានរៀបរាប់នៅក្នុងលក្ខខណ្ឌ និងខចែងទាំងនេះនឹងត្រូវគ្រប់គ្រងដោយ "លក្ខខណ្ឌ និងខចែងទូទៅ"។

## មាត្រា ២. ការប្រាក់

១. ការប្រាក់នៃគណនីត្រូវគណនាតាមវិធីសាស្ត្រមូលដ្ឋានដែលស្របទៅតាមប្រភេទនៃគណនីនីមួយៗ ហើយបញ្ចូលទៅក្នុងប្រាក់ដើមនៅថ្ងៃបន្ទាប់ (តទៅនេះហៅថា "កាលបរិច្ឆេទបញ្ចូលការប្រាក់")។ ទោះជាយ៉ាងនេះក្ដី មិនមានការប្រាក់បង្គរសម្រាប់គណនីចរន្តនោះទេ ហើយប្រសិនបើគណនីនោះបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលធនាគារបានកំណត់ទុកសម្រាប់គណនីមួយ ធនាគារនឹងមិនផ្ដល់ការប្រាក់ឡើយ។

ក. គណនីបញ្ញើតាមតម្រូវការ៖ ថ្ងៃធ្វើការចុងក្រោយនៃខែនីមួយៗ នៃឆ្នាំ។

២. ការប្រាក់លើគណនីបញ្ញើដែលបានផ្ដល់ជូនខាងលើត្រូវគណនាសម្រាប់រយៈពេលចាប់ពីថ្ងៃដាក់ប្រាក់ដំបូង ឬថ្ងៃបញ្ចូលការប្រាក់ រហូតដល់មុនថ្ងៃបញ្ចូលការប្រាក់បន្ទាប់ ឬថ្ងៃដកប្រាក់ ដោយអនុវត្តតាមអត្រាការប្រាក់ដែលដាក់បង្ហាញនៅធនាគារនៅថ្ងៃធ្វើការរហូតដល់សមតុល្យចុងក្រោយប្រចាំថ្ងៃ។
៣. ការប្រាក់លើគណនីបញ្ញើត្រូវទូទាត់ជូនដូចមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ចាប់ពីកាលបរិច្ឆេទប្រតិបត្តិការចុងក្រោយ ដោយមិនរាប់បញ្ចូលការទូទាត់ការប្រាក់ក្នុងកថាខណ្ឌទី ១ ហើយចំពោះគណនីអសកម្ម ការប្រាក់នឹងមិនត្រូវបានផ្ដល់ជូនចាប់ពីកាលបរិច្ឆេទនៃការចាត់ថ្នាក់ជាគណនីអសកម្ម។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីដែលអតិថិជនស្នើសុំឱ្យផ្លាស់ប្តូរគណនីអសកម្មទៅជាគណនីធម្មតាវិញ នោះការប្រាក់នឹងត្រូវបានគណនាចាប់ពីថ្ងៃប្ដូរនោះ និងបង់ការប្រាក់ជូនដោយផ្អែកលើកថាខណ្ឌទី ១។

## មាត្រា ៣. ប្រតិបត្តិការដោយប្រើប្រាស់មូលប្បទានប័ត្រ (គណនីចរន្ត)

១. អតិថិជនត្រូវធ្វើប្រតិបត្តិការជាមួយសមភាគីរបស់ខ្លួនដោយប្រើមូលប្បទានប័ត្រដែលផ្តល់ដោយធនាគារ។
២. តាមរយៈការស្នើសុំរបស់អតិថិជន ធនាគារនឹងផ្តល់ឱ្យអតិថិជននូវមូលប្បទានប័ត្រដូចដែលមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ។ ប៉ុន្តែធនាគារអាចកំណត់ទៅលើចំនួនមូលប្បទានប័ត្រដែលនឹងផ្តល់ជូន ក្នុងករណីដែលចំនួននៃការស្នើរសុំមូលប្បទានប័ត្ររបស់អតិថិជនមានលក្ខណៈលើសពីគោលការណ៍ដែលបានកំណត់ដោយធនាគារ។

## មាត្រា ៤. ការទូទាត់ និងការលុបចោលការស្នើសុំការទូទាត់

១. អនុលោមតាមកថាខណ្ឌទី ១ នៃមាត្រា ៣ ធនាគារត្រូវធ្វើការទូទាត់ទៅឱ្យអ្នកដែលបង្ហាញសែកទៅតាមចំនួនទឹកប្រាក់ដែលបានបញ្ជាក់នៅលើមូលប្បទានប័ត្រតាមការស្នើសុំទូទាត់របស់អតិថិជន។
២. ធនាគារត្រូវធ្វើការទូទាត់មូលប្បទានប័ត្រ លុះត្រាតែមូលប្បទានប័ត្រនោះតែត្រូវបានបង្ហាញក្នុងថ្ងៃដែលមានចារនៅលើមូលប្បទានប័ត្រនោះ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារក៏អាចធ្វើការទូទាត់បាន ទោះបីជាមូលប្បទានប័ត្រត្រូវបានបង្ហាញនៅថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៅលើមូលប្បទានបត្រក៏ដោយ។
៣. ក្នុងករណីដែលអតិថិជនចង់លុបចោលការស្នើសុំទូទាត់មូលប្បទានប័ត្រដែលបានចេញរួចហើយនោះ អតិថិជនត្រូវស្នើសុំការលុបចោលតាមសំណើរបស់អ្នកចេញមូលប្បទានបត្រ (ម្ចាស់គណនី/បុគ្គលដែលមានសិទ្ធិ) ជាមួយនឹងពាក្យស្នើរសុំជាលាយលក្ខណ៍អក្សរ និងតំរូវមកធនាគារដោយផ្ទាល់។

## មាត្រា ៥. លក្ខខណ្ឌពិសេសសម្រាប់ការទូទាត់

ទោះបីជាមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៤ ក៏ដោយ ក្នុងករណីដែលអតិថិជនជំពាក់ធនាគារក្នុងកាតព្វកិច្ចណាមួយក្នុងចំណោមកាតព្វកិច្ចទាំង ៤ ដូចដែលមានចែងខាងក្រោម ធនាគារអាចធ្វើការទូទាត់តាមរយៈការផ្ទេរប្រាក់ជាមុនពីគណនីដែលពាក់ព័ន្ធជាជាងពីគណនីផ្សេងទៀត ដោយមិនប្រើមូលប្បទានប័ត្រ ឬការស្នើរសុំសម្រាប់ការទូទាត់រួមមានៈ

ក. ការប្រាក់ផ្សេងៗ ថ្លៃធានា និងកម្រៃជើងសារ
ខ. ប្រាក់ដើមនៃការនាំចូល និងការនាំចេញដែលមិនគោរពតាមគោលការណ៍សមស្របណាមួយ
គ. ការផាកពិន័យក្រោមច្បាប់នៃសភាផាត់ទាត់ (សំរាប់មូលប្បទានបត្រគ្មានសមតុល្យ)
ឃ. ចំនួនទឹកប្រាក់ដែលទាមទារសម្រាប់ការទូទាត់ ឬសំណងណាមួយ។

ក្នុងករណីដែលធនាគារត្រូវបានស្នើសុំឱ្យទូទាត់មូលប្បទានប័ត្រ និងបំពេញកាតព្វកិច្ចក្នុងថ្ងៃតែមួយ បើសិនជាចំនួនទឹកប្រាក់សរុបលើសពីសមតុល្យដែលមាននៅក្នុងគណនីដែលពាក់ព័ន្ធ ធនាគារត្រូវដោះស្រាយករណីនេះស្របទៅតាមការណែនាំរបស់អតិថិជន ហើយប្រសិនបើអាចបញ្ជាក់ពីគោលបំណងរបស់អតិថិជន ធនាគារត្រូវដោះស្រាយតាមគោលការណ៍របស់ខ្លួន។

## មាត្រា ៦. ការបដិសេធនៃការទូទាត់ដោយផ្នែក

១.ធនាគារនឹងមិនធ្វើការទូទាត់មូលប្បទានប័ត្រដែលមានចំនួនទឹកប្រាក់លើសពីទឹកប្រាក់ដែលមាននៅក្នុងគណនីចរន្តនោះទេ(មិនរាប់បញ្ចូលសមតុល្យតម្កល់ដំបូង)
២. ធនាគារនឹងមិនធ្វើការទូទាត់ដោយផ្នែកសម្រាប់មូលប្បទានប័ត្រឡើយ។

## មាត្រា ៧. ការទូទាត់មូលប្បទានប័ត្រ និងអភ័យឯកសិទ្ធិ

១.ធនាគារមិនទទួលខុសត្រូវចំពោះការខាតបង់ណាមួយដែលកើតឡើងដោយអតិថិជនទាក់ទងនឹងការទូទាត់មូលប្បទានប័ត្រនៅក្នុងករណីដូចខាងក្រោម ហើយធនាគារត្រូវយកចិត្តទុកដាក់ចំពោះការទូទាត់មូលប្បទានប័ត្រក្នុងករណី៖

ក. ក្នុងករណីដែលធនាគារទូទាត់មូលប្បទានប័ត្រដែលមិនមានកាលបរិច្ឆេទនៃការចេញមូលប្បទានបត្រ

ខ.ក្នុងករណីដែលធនាគារទូទាត់មូលប្បទានប័ត្រដែលមិនមានកាលបរិច្ឆេទចេញ ឬកាលបរិច្ឆេទផុតកំណត់ ដោយចាត់ទុកកាលបរិច្ឆេទបង្ហាញមូលប្បទានបត្រជាកាលបរិច្ឆេទទូទាត់។

គ. ក្នុងករណីដែលធនាគារទូទាត់មូលប្បទានប័ត្រដែលមានស្នាមឆូតខ្វែង ជាមួយនឹងគំរូហត្ថលេខា ដែលត្រូវបានគេចាត់ទុកថាដូចគ្នាទៅនឹងគំរូហត្ថលេខា របស់អតិថិជន ដោយយោងតាមមាត្រា 5 កថាខណ្ឌទី 1 នៃ "លក្ខខណ្ឌ និងខចែងទូទៅ"។

## មាត្រា ៨. ការធ្វើប្រតិបត្តិការជាមួយភ្នាក់ងារ (អ្នកទទួលសិទ្ធិ)

១. នៅពេលដែលអតិថិជនធ្វើប្រតិបត្តិការតាមរយៈភ្នាក់ងារ (អ្នកទទួលសិទ្ធិ) ឈ្មោះ និងហត្ថលេខារបស់ភ្នាក់ងារដែលត្រូវប្រើលើមូលប្បទានប័ត្រត្រូវចុះបញ្ជីនៅធនាគារ។
២. នៅពេលអតិថិជនអនុញ្ញាតឱ្យភ្នាក់ងារចេញមូលប្បទានប័ត្រ ព័ត៌មានរបស់ភ្នាក់ងាររួមមានហត្ថលេខា និងទំនាក់ទំនងរវាងអតិថិជននិងភ្នាក់ងារត្រូវចុះបញ្ជីនៅធនាគារ។ ធនាគារអាចបដិសេធមិនទូទាត់មូលប្បទានប័ត្រដែលចេញដោយភ្នាក់ងារដែលមិនបានចុះបញ្ជីនៅធនាគារ។

## មាត្រា ៩. ការបិទគណនីចរន្ត

១. ក្នុងករណីដែលអតិថិជនបាត់បង់សិទ្ធិសម្រាប់ធ្វើប្រតិបត្តិការលើគណនីចរន្តដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ដូចជាចេញមូលប្បទានប័ត្រដែលមិនមានសមតុល្យមិនគ្រប់គ្រាន់លើសពី ៣ ដង ឬប្រសិនបើត្រូវបានចាត់ទុកថាមិនសមស្របក្នុងការបន្តធ្វើប្រតិបត្តិការគណនីចរន្តដោយផ្អែកលើលក្ខខណ្ឌ និងខចែងទាំងនេះ ធនាគារអាចផ្អាក រក្សាទុក បញ្ចប់កិច្ចព្រមព្រៀងប្រាក់បញ្ញើដែលពាក់ព័ន្ធ ដោយផ្តល់ការជូនដំណឹងជាមុនដល់អតិថិជន។

## មាត្រា ១០. កាតព្វកិច្ចបន្ទាប់ពីការបិទគណនីចរន្ត

បន្ទាប់ពីគណនីចរន្តត្រូវបានបិទ ធនាគារនឹងមិនមានកាតព្វកិច្ចទូទាត់មូលប្បទានប័ត្រណាមួយឡើយ បើទោះបីជាមូលប្បទានប័ត្រត្រូវបានចេញមុនការបិទគណនីចរន្តក៏ដោយ ហើយបន្ទាប់ពីបិទគណនីចរន្តអតិថិជនត្រូវបង្វិលសងមូលប្បទានប័ត្រដែលមិនទាន់ប្រើប្រាស់ទាំងអស់ទៅកាន់សាខាធនាគារដែលអតិថិជនបានបើកគណនីចរន្តវិញបន្ទាប់ពីបិទគណនីចរន្ត។

## មាត្រា ១១. ប្រាក់តម្កល់ដំបូង (សមតុល្យតម្កល់ទុក)

១. អតិថិជនត្រូវដាក់ប្រាក់តម្កល់ដំបូង ទៅតាមប្រភេទគណនីនីមួយៗ ដែលសម្រេចដោយធនាគារ។

២.ក្នុងករណីដែលធនាគារផ្លាស់ប្តូរចំនួនទឹកប្រាក់តម្កល់ដំបូងដូចដែលមានចែងក្នុងកថាខណ្ឌ ១ អនុវត្តតែចំពោះអតិថិជនដែលបើកគណនីចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃការផ្លាស់ប្តូរចំនួនទឹកប្រាក់តម្កល់ដំបូង។

៣. ប្រាក់តម្កល់ដំបូងនឹងត្រូវតម្កល់ទុក ហើយនៅពេលបិទគណនី ធនាគារត្រូវកាត់ទឹកប្រាក់តម្កល់ដំបូងក្នុងគណនីទៅធនាគារក្នុងករណីដែលអតិថិជនមានបំណុលដែលត្រូវទូទាត់ជាមួយធនាគារ។

៤. ធនាគារត្រូវទូទាត់ជូនអតិថិជនវិញនូវសមតុល្យដែលនៅសល់នៃប្រាក់តម្កល់ដំបូង (សមតុល្យតម្កល់ទុក) នៅពេលបញ្ចប់នីតិវិធីដែលមានចែងក្នុងកថាខណ្ឌទី ៣ ខាងលើ បន្ទាប់ពីប្រមូលវិញនូវមូលប្បទានប័ត្រដែលមិនទាន់បានប្រើប្រាស់ទាំងអស់ពីអតិថិជន។

៥. ទោះជាយោងទៅតាមកថាខណ្ឌទី ៤ ខាងលើក៏ដោយ ធនាគារនឹងទូទាត់ប្រាក់តម្កល់ដំបូង (សមតុល្យតម្កល់ទុក) ជូនអតិថិជនវិញ ប្រសិនបើមានហេតុផលសមស្របណាមួយ ដែលអតិថិជនមិនអាចប្រគល់មូលប្បទានប័ត្រដែលមិនទាន់បានប្រើប្រាស់មកធនាគារវិញ។

## មាត្រា ១២. ការផ្អាក ការបិទ ការបង្កកគណនី

១. ម្ចាស់គណនី/បុគ្គលដែលមានសិទ្ធអាចស្នើសុំការបញ្ចប់/បិទគណនីតាមរយៈការទៅកាន់ធនាគារដោយផ្ទាល់ដោយភ្ជាប់ជាមួយនឹងឯកសារពាក់ព័ន្ធ។

២. នៅពេលបិទគណនី អតិថិជនត្រូវផ្តល់ជូនធនាគារវិញនូវរាល់៖

ក. កាតដែលដំណើរការគណនី (រួមទាំងកាតដែលចេញឱ្យម្ចាស់ប័ណ្ណបន្ថែម)

ខ. មូលប្បទានបត្រដែលមិនទាន់បានប្រើប្រាស់ (សម្រាប់គណនីចរន្ត)

គ. សៀវភៅធនាគារ/វិញ្ញាបនបត្រផ្សេងៗ (ប្រសិនបើមាន)។

៣. ធនាគារអាចផ្អាកប្រតិបត្តិការធនាគារណាមួយនៃគណនីរបស់អតិថិជនដោយមិនចាំបាច់ជូនដំណឹងជាមុននៅក្នុងករណីដូចខាងក្រោម៖

ក. អតិថិជនមិនគោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងអស់ទាក់ទងនឹងប្រតិបត្តិការគណនី ដូចជាច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ខ. អតិថិជនបានរំលោភលើបទប្បញ្ញត្តិនៃច្បាប់ជាធរមាននៅក្នុងប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត ទាំងដោយផ្ទាល់ និងដោយប្រយោលពាក់ព័ន្ធនឹងការហាមឃាត់បុគ្គល ឬអង្គភាពដែលបានកំណត់ ឬសកម្មភាពខុសច្បាប់ ឬការផ្ទេរប្រាក់ចេញ-ចូលជាមួយប្រទេសដែលជាប់ការដាក់ទណ្ឌកម្ម។

## មាត្រា ១៣. ព័ត៌មានរបស់អតិថិជន និងការផ្ទៀងផ្ទាត់

១. អតិថិជនត្រូវជូនដំណឹងដល់ធនាគារអំពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន លេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីមែល។ដើម្បីធានាថាធនាគារនឹងចែករំលែកឯកសារសំខាន់ៗទាំងអស់ដែលទាក់ទងនឹងព័ត៌មានគណនីរបស់អតិថិជនទៅកាន់អាសយដ្ឋាន និងលេខទំនាក់ទំនងដែលត្រឹមត្រូវ។
២. រាល់ព័ត៌មានឯកជនភាពទាំងអស់របស់អតិថិជនត្រូវរក្សាទុកជាសម្ងាត់ ហើយនឹងត្រូវបានរក្សាទុកដោយសុវត្ថិភាពដោយធនាគារ។

## មាត្រា ១៤. វិធាន និងបទបញ្ញត្តិនៃស្ថាប័នពាក់ព័ន្ធ

អតិថិជនបានយល់ព្រមថា ចំពោះការបន្ថែម និងមិនប៉ះពាល់ដល់សិទ្ធដែលមានក្នុងលក្ខខណ្ឌ និងខចែង។ លក្ខខណ្ឌ និងខចែងនេះនឹងត្រូវគ្រប់គ្រង និងអនុលោមតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលធ្វើ កំណែទំរង់ដែលចេញដោយធនាគារជាតិនៃកម្ពុជា ។ ច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ រឺមិនពាក់ព័ន្ធផ្សេងទៀតដែលមានអំណាចដោយច្បាប់នៃព្រះរាជាណាចក្រនៃកម្ពុជា។

ខ្ញុំទទួលស្គាល់ថាបានអានលក្ខខណ្ឌ និងខចែងខាងលើតាមកាលបរិច្ឆេទនៃថ្ងៃនេះ ហើយខ្ញុំនឹងទទួលត្រូវ និងដឹងពីកត្តាហានិភ័យដែលមាននៅក្នុងលក្ខខណ្ឌ និងខចែងទាំងនេះ។

# SAVING ACCOUNT TERMS AND CONDITIONS

## Article 1. Application of Terms and Conditions

These terms and conditions apply to transactions with **Shinhan Bank (Cambodia) Plc,** (hereinafter refer to as the **"Bank"**) under **"Saving Account"** (hereinafter refer to as the **"Account"**).

## Article 2. Eligible for Subscription

This account is available for individual (age 18 or older), individual Business, Corporation, Bank/MFIs and Non-Government Organization (NGO).

## Article 3. Product Feature

| Categories | Contents |
|---|---|
| Product Type | Demand Deposit |
| Initial Deposit | USD0.00/KHR0.00 (can deposit any amount) |
| Currency | USD/KHR |
| Deposit Amount | No limitation |
| Interest Rate | Applied based on Standard Interest rate announced by the Bank (can inquiry through website: www.shinhan.com.kh) |
| The ways of Transaction | Deposit or withdrawal at any time up to the available account balance |
| Interest Payment | The Bank pays the interest to the customer monthly or upon account closure<br>(Interest Payment period: by end of each month of the year) |
| Early Closure | USD20.00/KHR80,000 for saving account closure below 3 months of opening date |
| Interest Income Tax | 4% for Resident/14% for Non-Resident |

| | |
|---|---|
| **Access to Deposit** | All SBC branches/ATM/Other Bank Channels |
| **Additional Benefit** | Free Annual Maintenance fee/Internet banking or Mobile Banking |

## Article 3. Operation of Deposits

This account is operated as saving deposit.

# TERMS AND CONDITIONS OF DEMAND DEPOSIT ACCOUNT

## Article 1. Scope of Application

1. The “Demand Deposit Account” refer to the “Account” shall mean any deposit account without any specified deposit period, allowing the Customer to do deposit(s)/withdrawal(s) at will.
2. Any matters not provided for under these Terms and Conditions shall be governed by the “General Terms and Conditions”.

## Article 2. Interest

1. The interest on the Account shall be computed on the relevant base day according to the type of account and added to the principle on the next day (hereinafter referred to as the “Interest Addition Date”). No interest shall however be accrued on the current account and if the account satisfies a certain criterion the Bank has set aside for an account, the Bank may not pay interest.
   a) Demand Deposit Account: the last business day of each month of the year.
2. The interest on deposit accounts provided above shall be calculated for the period from the date of the first deposit or the interest Additional Day to the date immediately preceding the next interest Additional Day or the withdrawal date by applying the interest rate posted at the Bank’s office on business days to daily final balances.
3. The Interests on deposit accounts shall be paid as provided in Paragraphs 1 and 2 from the last transaction date excluding payment of interests under Paragraph 1, and thereafter the account that turn to be Dormant Account and interests will not be provided from the date of classified as Dormant Account. However, in the case that customer request to release the Dormant Account to normal account, the interest will be calculated from the released date and provided based on Paragraph 1.

## Article 3. Transactions Using Cheque (Current Account)

1. The Customer shall transact with its counterparty using the cheque provided by the Bank.
2. Upon the request of the Customer, the Bank shall provide the Customer with the cheques described in Paragraph 1 above; provided that the Bank may restrict the number of forms of

cheque requested by the Customer as deemed appropriate by the Bank, if the requested number is deemed to be excessive with the rule of the Bank.

## Article 4. Payment and Cancellation of Request of Payment

1. Pursuant to Paragraph 1 to Article 3, the Bank shall pay to the presenter the amount specified on the cheque upon the Customer’s request for payment.
2. The Bank shall make payment for the cheque only if it is presented within the present date. However, the the Bank may make payments even if the cheque is presented after the present period.
3. In the case the Customer wished to cancel the request for payment for a cheque that already issued by the Customer, the Customer shall apply for such cancellation by the request of issuer (Account Holder/Authorized Person) with the written application from by visit the Bank.

## Article 5. Special Provision for Payment

Notwithstanding the provision of Paragraph 1 to Article 4, in case the Customer owes to the Bank any of the obligations set forth below, the Bank may pay or settle through transfer first from the relevant Account rather than from other accounts, without using cheque or application for payment includes:

a) Various interests, guarantee fees and commissions;
b) Principle amount of import bills and principle amount of dishonored export bills
c) Penalty fees under the Rules of the Clearing House (dishonored cheque)
d) The amount claimed by any settlement or reimbursement receipt.

In case the Bank is requested to pay the cheque and to perform the obligations on the same day, the total amount of which exceeds the fund available in the relevant Account, the Bank shall handle such case in accordance with the customer’s instruction, if any, and if it is possible to ascertain the Customer’s intent, the Bank shall handle it at its discretion.

## Article 6. Refusal of Partial Payment

1. The Bank shall not pay cheque with issue amount of which exceeds the fund available in the current account (excluding initial holding balance).
2. The Bank shall not make partial payment for a cheque.

## Article 7. Payment of Cheque and and Immunity

1. The Bank shall not be liable for any losses incurred by the Customer with respect to payment of cheque in the following cases; provide that the Bank shall take due care for payment of cheque in the case of;
   a) In case the Bank pays a cheque with the date of issue left blank,
   b) In case the Bank pays a cheque with respect to which the issue date or due date does not exist, treating the present date as the payment date.
   c) In case the Bank pay a cheque with cross line and with imprinted with the specimen, which specimen is deemed to be identical to the Customer's specimen pursuant to Article 5, Paragraph 1of the "General Terms and Conditions".

## Article 8. Transaction with Agent

1. When the Customer desires to conduct transactions through an agent, the name and the signature of the agent to be used in cheque shall be registered at the Bank.
2. When the Customer authorizes the agent to issue a cheque, the agent's information include specimen including specimen and the relationship between them shall be registered at the Bank. The Bank may refuse to pay a cheque issued by un-registered agent.

## Article 9. Termination of Current Account

1. In the case the Customer become disqualified for current account transaction based on the relevant laws and regulations such as issued cheque with insufficient fund for more than 3 times, or if it is deemed inappropriate to continue the current account transaction based on these Terms and Conditions, the Bank may suspend, hold, terminate the relevant deposit agreement by giving a prior notice to the Customer.

## Article 10. Obligation after Termination of Current Account

After the current account is closed, the Bank shall not be obligated to pay any of the cheques or notes even if they were issued before the termination, and the Customer shall return to the account opening branch any unused forms of cheques and notes.

## Article 11. Initial Deposit (Holding Balance)

1. The customer shall deposit the initial deposit amount based on each account type, decided by the Bank.
2. In case the Bank changes the required amount of the initial deposit referred to in Paragraph 1 it will apply to the Customer that open account based on the date from the effective date only.
3. Initial deposit will be hold and Upon closing of the Account, the Bank shall deduct the amount owed by the Customer to the Bank in connection with Account from the initial deposit.
4. The Bank shall return any remaining balance of the initial deposit (hold balance) upon completion of the procedures described in Paragraph 3 above, after recovering the all remaining unused cheque from the Customer.
5. Notwithstanding pursuant to Paragraph 4 above, the Bank shall return the initial deposit (hold balance) if there is any reasonable cause for which the Customer cannot return the unused cheque.

## Article 12. Suspension, Close, Freeze of the Account

1. Account Holder(s)/Authorized Person(s) can request for the termination/closure by visiting the Bank with related documents.
2. When close account, the Customer must provide to the Bank with any:
   a) Card that operates the account (including any card issued to an additional cardholder).
   b) Unused remain cheque (for current account).
   c) Passbook/certificate (if any).
3. The Bank may suspend or the banking transaction any of the Customer's account(s) without prior notice in the following cases
   a) The Customer do not comply with all applicable laws, rules and regulations in connection with account operation such as Law on Anti-Money Laundering and Combating the Financial of Terrorism.
   b) The Customer violated provisions of applicable law in Cambodia or any other country both directly and indirectly involve with any designated individual or entity prohibition or any illegal activities or transfer in-out with sanction countries.

## Article 13. Customer Information and Verification

a) The Customer shall notify the Bank of any change in current address, telephone number or E-mail address. This will ensure that the Bank to share all important documents related to the Customer's account information to the correct address and contact.
b) All privacy information of the Customer shall be kept in strict confident and will be securely held by the Bank.

## Article 14. Rules and Regulations of Related Bodies

The Customer agree that in addition and without prejudice to any of the terms and conditions herein, where applicable the terms and conditions herein shall be governed by and subjected to the rules, regulations and guidelines updated from time to time issued by National Bank of Cambodia, and other relevant bodies whether or not such rules, regulations and guidelines have the force of laws of Kingdom of Cambodia.

My signature acknowledges that I have read the terms and conditions above as the date of today, and I am aware of the risk factors contained in these terms and conditions.